បេសកម្មរបស់យើង

ការផ្លាស់ប្តូរការរស់នៅ ដោយការផ្តល់ការគាំទ្រ និងជំរុញភាពជាដៃគូដែលផ្តល់អំណាយឱ្យមនុស្សរស់នៅតាមជីវិតដែលពួកគេចង់បាន។

តម្លៃរបស់យើង

ការគោរព ដែលទទួលបានតាមរយៈការទទួលស្គាល់ជាវិជ្ជមានទៃសារៈសំខាន់របស់បុគ្គលទាំងអស់

ការផ្វើផែនការផ្តោតលើបុគ្គល ដើម្បីគាំទ្របុគ្គលនីមួយៗ ឱ្យឈានដល់សក្តានុពលរបស់គាត់ ឬនាង

ភាពជាដៃគូ រវាង DDA និងអតិថិជន គ្រួសារ និងអ្នកផ្តល់សេវាដើម្បីអភិវឌ្ឍ និងទ្រទ្រង់ការគាំទ្រ និងសេវាកម្មដែលត្រូវការ និងចង់បាន

ការចូលរួមក្នុងសហគមន៍ដោយផ្តល់អំណោចឱ្យបុគ្គលម្នាក់ៗដែលមានពិការភាពខាងការលូតលាត់ឱ្យក្លាយជាផ្នែកនៃកម្លាំងពលកម្ម និងរួមចំណែកជាសមាជិកសង្គម។

ចក្ខុវិស័យរបស់យើង

ការគាំទ្របុគ្គលម្នាក់ៗ ឱ្យរស់នៅ រួមចំណែក និងចូលរួមក្នុងសហគមន៍របស់ពួកគេ

បន្តពង្រឹងការគាំទ្រ ដល់ទាំងគ្រួសារកុមារ និងមនុស្សពេញវ័យ

ការតម្រូវតាមបុគ្គលចំពោះការគាំទ្រ ដែលនឹងផ្តល់អំណាចដល់បុគ្គលដែលមានពិការភាពខាងការលូតលាស់ដើម្បីយល់ដឹងពីសក្តានុពលល្អបំផុតរបស់ពួកគេ

ការកសាងផែនការគាំទ្រផ្អែកលើតម្រូវការ និងភាពខ្លាំងរបស់បុគ្គល និងគ្រួសារ និង

ការភ្ជាប់ពាក់ព័ន្ធបុគ្គលម្នាក់ៗ បណ្តាគ្រួសារ អ្នកផ្តល់សេវាក្នុងតំបន់ដៃគូរដ្ឋាភិបាលសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីបន្តពង្រឹងប្រព័ន្ធគាំទ្ររបស់យើង។

ទាក់ទងយើង

ចូលមើលលើបណ្តាញ ៖
dshs.wa.gov/dda/service-and-information-request
ស្វែងរកការិយាល័យ ៖
dshs.wa.gov/DDA/dda/ find-an-office
ទូរស័ព្ទមកយើង ៖

ខោនធី	ទូរស័ព្ទ
Chelan, Douglas, Ferry, Grant, Lincoln, Okanogan, Pend Oreille, Spokane, Stevens	(800) 319-7116
Adams, Asotin, Benton, Columbia, Franklin, Garfield, Grant, Kittitas, Klickitat, Walla Walla, Whitman, Yakima	(866) 715-3646
Island, San Juan, Skagit, Snohomish, Whatcom	(800) 567-5582
King	(800) 974-4428
Kitsap, Pierce	(800) 735-6740
Clallam, Clark, Cowlitz, Grays Harbor, Jefferson, Lewis, Mason, Pacific, Skamania, Thurston, Wahkiakum	(888) 707-1202

អ្នកដែលត្រូវការជំនួយជាមួយបណ្តឹង ឬសហគមន៍អាចទូរស័ព្ទទៅសេវាបញ្ជូនបន្ត ទូរគមនាគមន៍វ៉ាស៊ីនតោនដោយចុចទៅលេខ 7-1-1 ឬ 1-800-833-6388 (TTY)។

វាគឺជាគោលការណ៍របស់ DSHS ដែលបុគ្គលម្នាក់ៗនឹងមិនត្រូវបានរើសអើងប្រឆាំង (ក្នុងការងារ ឬសេវាកម្ម) ព្រោះតែពូជសាសន៍ ពណ៌សម្បុរ សាសនា ជំនឿ ដើមកំណើតជនជាតិ ទំនោរផ្លូវភេទ អាយុ ភេទ វត្តមានអារម្មណ៍ណាមួយ ពិការភាពផ្លូវចិត្ត ឬរាងកាយ ការប្រើគ្នែនាំផ្លូវ ឬសេវាសត្វដោយមនុស្សពិការ ឬស្ថានភាពអតីតយុទ្ធជន។

Washington State Department of Social & Health Services
Transforming lives

DSHS 22-722 CA (Rev. 9/18) Cambodian

ការណែនាំអំពី ភាពមានសិទ្ធិទទួលបាន ការគាំទ្រ និងសេវាកម្ម

Washington State Department of Social & Health Services
Transforming lives

រដ្ឋបាលពិការភាពខាងការលូ គលាស់

ភាពមានសិទ្ធិទទួលបាន DDA

ដាក់ពាក្យសុំភាពមានសិទ្ធិទទួលបានរដ្ឋបាលពិការភាពខាងការលូតលាស់ (DDA) បើអ្នក ឬកូនរបស់អ្នកមានមួយក្នុងចំណោមលក្ខខណ្ឌនានាខាងក្រោម។

ភាពមានសិទ្ធិទទួលបានតាមអាយុ	0-3 ឆ្នាំ	4-9 ឆ្នាំ	10-17 ឆ្នាំ	18 ឆ្នាំឡើងទៅ
មួយការពន្យារពេលខាងការលូតលាស់	✓			
២ ឬច្រើនការពន្យារពេលខាងការលូតលាស់	✓	✓		
ពិការភាពខាងបញ្ញា		✓	✓	✓
ពិការខ្លួនក្បាល		✓	✓	✓
ជំងឺឆ្លួតជ្រូក		✓	✓	✓
ជំងឺសរសៃប្រសាទ		✓	✓	✓
សរសៃប្រសាទផ្សេងទៀត ឬជំងឺផ្សេងទៀតដែលស្រដៀងនឹងពិការភាពខាងបញ្ញា		✓	✓	✓

ដើម្បីរកឃើញថាមានសិទ្ធិទទួលបាន DDA អ្នកត្រូវតែ ៖

- ជាអ្នករស់នៅរដ្ឋវ៉ាស៊ីនតោន
- មានភស្តុតាងអំពីពិការភាពខាងការលូតលាស់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចាប់ផ្តើមមុនអាយុ 18 ឆ្នាំ និង
- មានភស្តុតាងនៃវិធីកំណត់នានាជាច្រើន។

ស្វែងយល់បន្ថែមអំពីភាពមានសិទ្ធិទទួលបាន DDA នៅ ៖
www.dshs.wa.gov/dda/consumers-and-families/eligibility

សម្រាប់ព័ត៌មានបន្ថែម
ចូលមើលគេហទំព័រ DDA នៅ ៖
www.dshs.wa.gov/dda

តើសេវាកម្មមួយចំនួនដែល DDA ផ្តល់ឱ្យមានអ្វីខ្លះ?

- អន្តរាគមន៍ជំបូងសម្រាប់កុមារ ពីពេលកើតដល់អាយុបីឆ្នាំ
- ការថែទាំផ្ទាល់ខ្លួន និងការថែទាំសង្គ្រោះ
- ការថែទាំពេលសម្រាក
- ការបណ្តុះបណ្តាលជំនាញលទ្ធកម្ម
- ជំនួយបច្ចេកវិទ្យា
- ការឆ្លើយតបគ្រាអាសន្នផ្ទាល់ខ្លួន
- ការបណ្តុះបណ្តាលការគ្រប់គ្រងអ្នកផ្តល់ការថែទាំ
- សេវាកម្មផ្ទាស់ប្តូរសហគមន៍
- ប្រតិភូគិលានុបដ្ឋាយិកា
- គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់
- ការចូលទៅកាន់សហគមន៍
- ការកែប្រែផ្ទះ និងយានយន្ត
- គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់
- សម្ងៀកបំពាក់ឯកទេស
- ការប្រឹក្សា និងការគាំទ្រគរិយាបថ
- ការមើលថែទាំ
- ការចូលរួមក្នុងសហគមន៍
- សេវាកម្មលំនៅដ្ឋាន
- សេវាទប់ស្កាត់វិបត្តិ អន្តរាគមន៍ និងស្ថិរភាព
- ការធ្វើផែនការផ្តោតលើបុគ្គល
- ការគាំទ្រមាតាបិតាសម្រាប់អតិថិជន
- ការណែនាំដូច

ការចូលរួមក្នុងសេវាកម្ម DDA គឺដោយស្ម័គ្រចិត្ត

DDA ទិតខំអនុវត្តគោលការណ៍សាធារណៈដែលទំនៀមទម្លាប់លើកតម្លៃបុគ្គល គោរពខ្លួនឯង និងសេចក្តីថ្លៃថ្នូរបុគ្គលទីមួយ។ គឺមានតម្លៃជាសមាជិកដែលរួមចំណែកនៃសហគមន៍។ មូលនិធិរដ្ឋ និងសហព័ន្ធត្រូវបានប្រើដើម្បីផ្តល់ការគាំទ្រ និងសេវាកម្មសម្រាប់បុគ្គលដែលមានសិទ្ធិទទួល និងក្រុមគ្រួសាររបស់ពួកគេ។ ធនធានគឺមានកម្រិត ហើយសេវាដែលត្រូវការអាចមិនតែងតែរកប្រើបានឡើយ។

ការចូលប្រើសេវាកម្មនានាផ្នែកលើ ៖

- ការចំពេញបានតាមតម្រូវការភាពមានសិទ្ធិទទួលបានសម្រាប់សេវាកម្មជាក់លាក់មួយ
- តម្រូវការដែលបានវាយតម្លៃសម្រាប់សេវាកម្ម និង
- មូលនិធិអាចរកបានសម្រាប់សេវាកម្ម។

សំណួរចោទសួរជាញឹកញាប់

តើខ្ញុំដាក់ពាក្យសុំភាពមានសិទ្ធិទទួលបាន DDA ដោយរបៀបណា ឬបើខ្ញុំជាអតិថិជន DDA រួចហើយ តើខ្ញុំអាចស្នើសុំសេវាកម្មដោយរបៀបណា?

ចូរទូរស័ព្ទមកយើងតាមលេខមួយក្នុងចំណោមលេខនៅក្នុងឥត្តម្ចាស់ ឬចូលទៅលើបណ្តាញនៅ ៖ www.dshs.wa.gov/dda/service-and-information-request។

តើខ្ញុំអាចស្វែងរកអ្នកផ្តល់សេវាម្នាក់ដោយរបៀបណា?

ចម្លើយ ៖ ទាក់ទងអ្នកគ្រប់គ្រងករណីរបស់អ្នក។ ពួកគេអាចផ្តល់ឱ្យអ្នកនូវបញ្ជីអ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬផ្តល់ឧបករណ៍ស្វែងរកដើម្បីកំណត់គោលដៅអ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងតំបន់របស់អ្នក។

តើ DDA ផ្តល់ជូនសេវាពេលមានវិបត្តិ / គ្រាអាសន្នដែរទេ?

ប្រសិនបើអ្នកនៅក្នុងដំណើរការដាក់ពាក្យសុំសម្រាប់ភាពមានសិទ្ធិទទួលបាន DDA, DDA អាចជួយជាមួយការបញ្ជូនព័ត៌មាន និងចូលប្រើសេវាកម្មមួយចំនួន ខណៈពេលពាក្យសុំរបស់អ្នកកំពុងត្រូវបានពិនិត្យ។ បើសិនអ្នកមានសិទ្ធិទទួលបាន DDA រួចហើយ ចូរទាក់ទងអ្នកគ្រប់គ្រងករណីរបស់អ្នក។

តើការគាំទ្រអ្វីអាចរកបានសម្រាប់កុមារក្រោមអាយុបីឆ្នាំ?

អន្តរាគមន៍ជំបូងត្រូវបានផ្តល់ជាផ្នែកនៃការគាំទ្រជំបូងសម្រាប់ទារក និងកម្មវិធីកូនក្មេងក្នុងភាពជាដៃគូជាមួយនាយកដ្ឋានសិក្សាជំបូង និងទីភ្នាក់ងារទាំមុខក្នុងតំបន់។ ដើម្បីស្វែងយល់បន្ថែម ចូរទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍សុខភាពគ្រួសារតាមលេខ (800) 322-2588 ឬចូលលើបណ្តាញ នៅ ៖ Parenthelp123.org។ សួរអ្នកគ្រប់គ្រងករណីរបស់អ្នកថាតើសេវាផ្សេងទៀតអាចរកបានដែរឬយ៉ាងណា។